# ឧបោសថាគារ ឬវិហារបុរាណវត្តបុទុមវង្សី

ឧបោសថាគារ ជាអគារដែលមានព័ទ្ធសីមា សម្រាប់ភិក្ខុសង្ឃប្រជុំគ្នាធ្វើសង្ឃកម្ម ហើយដែលសព្វថ្ងៃខ្មែរហៅថា "វិហារ"។[១] ពាក្យឧបោសថាគារ ឃើញនៅប្រើលើខ្លោងទ្វារវិហារបុរាណវត្តបុទុមវង្សី ស្ថិតនៅក្នុងឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ យោងតាមខ្លឹមសារចារឹកកត់ចំណាំខ្លីមួយនៅលើខ្លោងទ្វារនោះដែរញ្ជាក់ថា វិហារបុរាណនេះកសាងក្នុងពុទ្ធសករាជ២៤៦៩ (គ.ស.១៩២៦) សង់អំពីឈើ និងកំបោរបាយអ ហើយមានតឹកតាងថែទាំជួសជុលជាបន្តបន្ទាប់រហូតគង់វង្សមកដល់សព្វថ្ងៃ នៅទន្ទឹមនឹងវិហារថ្មីដែលសង់នៅក្នុងឆ្នាំ១៩៩៥។

វិហារបុរាណវត្តបុទុមវង្សីមានទទឹងប្រហែល១០ម៉ែត្រ បណ្ដោយប្រហែល១៩ម៉ែត្រ ហើយដើមឡើយទំនងកសាងនៅលើខឿនថ្នាក់ៗ ដែលមានជណ្ដើរឡើងគ្រប់ទិស។ ប៉ុន្តែនៅក្នុងឆ្នាំ១៩៩០ ខឿនថ្នាក់ទី២ (ខាងលើ) បានចាក់បេតុងពង្រីកផ្លាដើរប្រទក្សិណ ព្រមទាំងលម្អដោយបង្កាន់ដៃនាគជណ្ដើរឡើងផង។ ក្នុងឆ្នាំ២០១៨ ខឿនថ្នាក់ទី១ (ខាងក្រោម) បានពង្រីកឱ្យកាន់តែទូលាយ និងរៀបចំក្រាលថ្ម ព្រមទាំងដាក់បង្កាន់ដៃនាគព័ទ្ធជុំវិញ ឱ្យក្លាយជាផ្លាស្មើគ្នារួមជាមួយវិហារថ្មី (រូបលេខ១-២)។ ប៉ុន្តែទោះបីមានស្លាកស្នាមកែលម្អច្រើនលើកច្រើនគ្រាយ៉ាងណាក៏ដោយ ទម្រង់រចនាសម្ព័ន្ធសំណង់វិហារចាស់នេះ ហាក់នៅរក្សាលក្ខណៈដើមច្រើន ពិសេសគឺរចនាសម្ព័ន្ធដំបូលវិហារ និងផ្នែកខាងក្នុង។



រូបលេខ១-២ វិហារបុរាណវត្តបុទុមវង្សី ដែលស្ថិតនៅទន្ទឹមនឹងវិហារថ្មី

[១] ជួន ណាត និងអ្នកដទៃ ១៩៦៧: ១៨១២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

*ទម្រង់វិហារវត្តបុទុមវង្សី ជាប្រភេទវិហារជហ្វាបួន ឬហៅថាវិហារបុរាណ។[២] វិហារនេះមានលក្ខណៈសាមញ្ញ និងពុំសូវតុបតែងក្បូរក្បាច់រចនាច្រើនឡើយ។ ដំបូលប្រក់ក្បឿងស្រកាលេញ រាងជ្រាលពីរថ្នាក់សងខាង ហើយដំបូលមុខក្រោយផ្នែកខាងក្រោមហោជាងរាងជ្រាលមួយថ្នាក់។ ចុងមេដំបូលមុខបំពាក់ជហ្វាពីរ ចុងមេដំបូលក្រោយបំពាក់ជហ្វាពីរ ព្រមទាំងមានលម្អដោយនាគដងក្ដារតាមចុងចែងនីមួយៗ។ រីឯរងស្បូវព័ទ្ធជុំវិញគេប្រើជាបន្ទះក្ដារធម្មតា ពុំមានក្បាច់រចនាអ្វីទេ (រូបលេខ៣)។*



KHMER CIVILIZATION

***រូបលេខ៣ ដំបូលវិហារបុរាណវត្តបុទុមវង្សី***

*ដោយឡែកចំពោះហោជាងទាំងសងខាងនៃវិហារ ជាប្រភេទហោជាងរៀបឥដ្ឋបូកកំបោរបាយអមានលក្ខណៈត្រង់ស្មើជញ្ជាំង។ សព្វថ្ងៃហោជាងខាងកើតស្ថិតនៅកំបាំងនឹងស្លឹកពោធិមួយភាគធំ តែនៅអាចមើលឃើញខ្លះថា គេរចនាជាក្បាច់យ៉ាងសាមញ្ញរំលេចជុំវិញទេពមួយអង្គ(?) ទ្រង់មកុដ បង្ហាញត្រឹមពាក់កណ្ដាលព្រះកាយ ព្រះហស្ដប្រណម្យ។ នៅតាមទងក្បាច់ខ្លះ មានលម្អដោយរូបបក្សាបក្សីផ្សេងៗផង (រូបលេខ៤)។*

---

*[២] ព្រាប ចាន់ម៉ារ៉ា ២០១៧: ១៣-២៣*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

រីឯហោជាងផ្នែកខាងលិច  ក៏មានលក្ខណៈប្រហាក់ប្រហែលហោជាងខាងកើតដែរ ពោលគេពុំប្រើក្បាច់ចាក់ពុម្ពស៊ីម៉ង់ត៍ទេ តែហោជាងនេះគេរចនាលម្អដោយក្បាច់ផ្កាភ្ញីព័ទ្ធជុំវិញបល្ល័ង្កខ្ពស់មួយ ដែលមានដំរីក្បាលបីនៅពីលើ ព្រមទាំងមានទេពមួយអង្គគង់លើដំរីនេះ (រូបលេខ២៩)។ បើតាមកាត់ស្មាន ទេពមួយអង្គគង់លើដំរីក្បាលបីនេះប្រហែលជាព្រះឥន្ទ្រគង់លើដំរីឰរាវ័ណ ដែលយើងតែងសង្កេតឃើញថាខ្មែរនិយមឆ្លាក់លម្អតាមផ្នែកផ្សេងៗនៃសំណង់ប្រាសាទបុរាណនានា តាំងពីសម័យមុនអង្គររហូតមក។[៣] ចំពោះរចនាសម្ព័ន្ធជញ្ជាំងវិហារ យើងសង្កេតឃើញមានទ្វារចំហៀងម្ខាង៣ និងទ្វារមុខក្រោយម្ខាង២ (សរុប១០ទ្វារ) តែពុំមានបង្អួចដូចវិហារបុរាណផ្សេងៗ។ នៅលើទ្វារខាងមុខក្រោយទាំងបួនគេបានរចនាដោយក្បាច់លម្អបន្តិចបន្តួច តែទ្វារចំហៀងទាំង៦ ជាទ្វារលាត។



រូបលេខ២៨ ការរចនាលម្អលើហោជាងខាងកើត



រូបលេខ២៩ ការរចនាលម្អលើហោជាងខាងលិច

ចំណែកឯផ្នែកខាងក្នុងវិហារ ត្រង់ចុងខាងលិចបំផុតនៃល្វែងគ្រឹះ មានបដិមាព្រះជីវ៍ធំមួយអង្គតម្កល់ខ្ពស់ជាងគេបង្អស់លើបល្ល័ង្កបីថ្នាក់(រូបលេខ២៦)។  បដិមាព្រះជីវ៍អង្គនេះសាងអំពីស៊ីម៉ង់ត៍ ក្នុងកាយវិហារផ្ចាញ់មារ តែលើផ្ទៃជញ្ជាំងខាងក្រោយ ជាគំនូរដើមពោធិ និងទេសភាពទឹកជ្រោះ ដែលប្លែកពីវិហារភាគច្រើននៅត្រង់ផ្ទៃជញ្ជាំងខាងក្រោយព្រះជីវ៍ គេតែងគូរត្រង់អន្ទើព្រះផ្ចាញ់មារ និងរូបនាងគង្ហីងព្រះធរណីលើបល្ល័ង្ក។[៤]

---

[៣] សូមអាន "ដំរីឰរ៍តក្នុងសិល្បៈខ្មែរ" ដោយ សុខ កែវវណ្ណារ៉ា ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/505 ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១

[៤] ព្រាប ចាន់ម៉ារ៉ា ២០១៥: ២៤-៣០

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៦ ព្រះដីវក្នុងកាយវិការផ្ចាញ់មារ និងព្រះពុទ្ធបដិមាក្នុងកាយវិការផ្សេងៗទៀតក្នុងវិហារវត្តបុទុមរង្សី

នៅផ្នែកខាងក្នុងវិហារនេះដែរ មានសសរឈើពីរជួររត់ត្រង់អមសងខាងល្វែងគ្រឹះ និងសសរឈើជាប់ជញ្ជាំងជុំវិញ ទល់ទ្រគ្រឿងបង្គុំឈើផ្សេងទៀតនៅផ្នែកខាងលើ។ តាមការសង្កេត សសរមួយចំនួនដែលប្រើក្នុងវិហារនេះច្រើនជាសសរចាស់ធ្លាប់ប្រើ ដ្បិតមានស្នាមត្រណាប់ និងស្នាមតជាដើម។ ប៉ុន្តែយ៉ាងណាក៏ដោយ សសរទាំងនោះសុទ្ធតែដាក់តម្កល់លើជើងសសរបេតុងកម្ពស់ប្រហែលកន្លះម៉ែត្រ ហើយត្រង់មុខតំណ ឬស្នាមដាប់ គេប្រើបច្ចេកទេសបំពេញដោយសាច់ឈើ ឬស៊ីម៉ងត៍ រួចលាបលន និងគូរក្បាច់លម្អពីលើយ៉ាងរស់រវើកស្ទើរមើលពុំដឹង (រូបលេខ៧-៩)។

រីឯពិតាន ពុំមានលាបពណ៌ ឬគូរលម្អជាគំនូរ ឬសាច់រឿងអ្វីឡើយ ពោលជាពិតានឈើធម្មតា ហើយសន្ទឹកក្តារនីមួយៗនៃពិតានរៀបទទឹងបន្តគ្នារហូតពេញល្វែងគ្រឹះ ពីលើព្រះដីវិពយរហូតដល់ក្រោមគល់ហោជាងខាងកើត (រូបលេខ១០)។ ការនិយមប្រើពិតានឈើបែបនេះ យើងសង្កេតឃើញមានតាមបណ្តាវិហារបុរាណជាច្រើនផ្សេងទៀតដែរ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៧-៩ សសរវិហារវត្តបុទុមវង្សី និងការគូរក្បាច់លម្អផ្សេងៗ



រូបលេខ១០ ពិតានឈើនៃវិហារវត្តបុទុមវង្សី

គំនូរវិហារបុរាណវត្តបុទុមវង្សី ជាគំនូរនិយាយអំពីរឿងពុទ្ធប្រវត្តិ និងរឿងជាតក ដូចបណ្ដាវិហារទូទៅដែរ។ បើផ្អែកលើសំណេរលើផ្ទាំងគំនូរក្នុងវិហារឱ្យដឹងថា ចាប់ផ្ដើមសាងសង់ដើមឆ្នាំ១៩៨៤ (រូបលេខ១១)។ ក្នុងន័យនេះ ប្រហែលបញ្ជាក់អំពីការចាប់ផ្ដើម

សាងសង់បន្តក្រោយសម័យសង្គ្រាម ដូចជាការជួសជុល និងគូរគំនូរជាដើម។ លើសពីនេះ នៅរាងឆ្នាំ១៩៩២ គេឃើញមានតឹកតាងគូរបន្ថែមត្រង់ចន្លោះខ្វះទៀត ជាពិសេសគឺគំនូរក្នុងរឿងជាតកជាដើម (រូបលេខ១២-១៣)។



រូបលេខ១១ គំនូររឿងពុទ្ធប្រវត្តិគូរឆ្នាំ១៩៨៤



រូបលេខ១២-១៣ គំនូររឿងជាតកគូរក្នុងរាងឆ្នាំ១៩៩២

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

សរុបមក វិហារបុរាណវត្តបុទុមវង្សី ជាសំណង់ពុទ្ធសាសនាដ៏សំខាន់ មានអាយុកាលជិត១០០ឆ្នាំ ដែលបានប្រើប្រាស់សម្ភារៈសំណង់ចាស់សម្រាប់សាងសង់ ហើយជាវិហារពុំសូវមានក្បាច់រចនាលម្អលើសំណង់ស្ថាបត្យកម្មច្រើនឡើយ។ ទន្ទឹមនឹងនេះ តាមរយៈគំនូរលើជញ្ជាំងបង្ហាញឱ្យថាវិ ហារនេះក្រោយបានសាងសង់ហើយភ្លាម គេពុំបានគូររឿងពុទ្ធប្រវត្តិ ឬរឿងជាតកផ្សេងៗទេ។ ទិដ្ឋភាពនេះ យើងសង្កេតឃើញមាននៅវិហារបុរាណផ្សេងៗទៀតដែរ។ ប៉ុន្តែយ៉ាងណាក្តី សព្វថ្ងៃវិហារនេះហាក់មានសភាពទ្រុឌទ្រោមខ្លាំង ប្រេះជញ្ជាំង របើកការ៉ូបាត និងមានកណ្តៀរស៊ីបំផ្លាញឈើដោយអន្ទើៗ៕

## ឯកសារយោង


ជួន ណាត និងអ្នកដទៃ

១៩៦៧, *វចនានុក្រមខ្មែរ ភាគ១-២*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា

២០១៥, "ផ្កាញ់មារ" *កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ*, ទំ. ២៤-៣០, យសោធរ, ភ្នំពេញ

២០១៧, *ទម្រង់សំណង់ប្រពៃណីខ្មែរ៖ សំណង់នៅតាមវត្ត ភាគ១*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

សុខ កែវវណ្ណារ៉ា

២០២១, "ដំរីព្វាវ័តក្នុងសិល្បៈខ្មែរ" ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/505 ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត